អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបង្កើតហ្គីតា**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតរូបភាព

៖ គំនូរនិងសកម្មភាពកសាង៖

ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

ប្រាប់បានពីរបៀបធ្វើចលនាដៃដោយការទប់លំនឹង

និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងអ្វីមួយ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

៖ វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក

កាត់ បិទបត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សម្ភារដែលត្រូវត្រៀមមាន៖ ដបទឹកសុទ្ធធំ ក្បាលមាន់ចោះរន្ធ ហ្វីត កាំបិត ចង្កឹះ ខ្សែ កន្ត្រៃ

**ការរៀបចំ** ៖ បង្កើតជាហ្គីតាមួយសម្រាប់បង្ហាញទៅកាន់កុមារ មុននឹងឱ្យកុមារចាប់ផ្ដើមលេង ឬបង្កើត

នៅក្នុងថ្នាក់ទាំងអស់គ្នា។

**សេចក្ដីណែនាំ** ៖

1. ដំបូងសួរកុមារពីឧបករណ៍តន្ត្រីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន? តើកូនៗស្គាល់ហ្គីតាដែរឬទេ?
2. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះពួកយើងនឹងបង្កើតឧបករណ៍តន្ត្រីមួយដែលមានឈ្មោះថា ហ្គីតា។
3. ចាប់ផ្តើមប្រាប់កុមារពីរបៀបនៃការធ្វើហ្គីតាដោយខ្លួនឯង
    - ❖ យកដបទឹកសុទ្ធមួយ ប្រើហ្វឺតគូរទំហំនៅលើដបសម្រាប់កាត់ឱ្យបានស្អាត
    - ❖ កាត់វាតាមអ្វីដែលបានគូរ (អាចប្រើកន្ត្រៃ ឬអ្វីក៏បានដែរដែលអាចកាត់បាន)។
    - ❖ ប្រើក្បាលមាន់ ឬឧបករណ៍មុតស្រួច ចោះវាទាំងក្បាលទាំងគូទរបស់ដប
    - ❖ កាត់ឈើចង្កឹះ ២ប្រវែង មានខ្លីនិងវែង
    - ❖ ប្រើខ្សែអំបោះចងឈើចង្កឹះវែងមួយសិន
    - ❖ ស៊កខ្សែចូលទៅក្នុងរន្ធពីក្បាលដបនិងគូទដប
    - ❖ ចងជាមួយឈើចង្កឹះខ្លីមួយទៀត (តែបញ្ជាក់ ចងកុំសូវតឹងពេក)
    - ❖ យើងអាចរឹតវាឱ្យតឹងបាន (ដើម្បីប្តូរសំឡេង ទៅតាមកម្រិតតឹង ឬធូររបស់ខ្សែដែរ)
    - ❖ នេះជាការលេងសាកល្បង បន្ទាប់ពីបានបង្កើតវារួចរាល់។
    - ❖ ហ្គីតានេះ វានឹងផ្លាស់ប្តូរសំឡេងនៅពេលដែលយើងបានរឹតវា ឬបន្ធូរវាផងដែរ។
4. ការបង្កើតហ្គីតានេះ វាមិនមែនជាការបង្កើតឱ្យដូចជារបស់ពិតនោះទេ គ្រាន់តែប្រដៀង និងអាចលេងបានតែប៉ុណ្ណោះ។
5. អ្នកអាចបង្កើតដោយប្រើដបទឹកសុទ្ធនិងសម្ភារផ្សេងៗទៀតក៏បានដែរ សម្ភារដែលអ្នកអាចឬងាយនឹងរកបានផងដែរ។